# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃព្រហស្បតិ៍ ១៥រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០២៥

## សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ពិធីបើកដំណើរការកម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថលរដូវកាលទី ៤

នាថ្ងៃ ព្រហស្បតិ៍ ទី ២៧ ខែ មីនា ឆ្នាំ ២០២៥, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (ម.ធ.ត.) បានរៀបចំ ពិធីបើកដំណើរការជាផ្លូវការនៃ**កម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថលរដូវកាលទី ៤** ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត តាំង ខួនលី នាយកប្រតិបត្តិ នៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"** ដោយមានការចូលរួមពីសំណាក់អ្នកតំណាងដៃគូសហការនៃកម្មវិធីរួមមាន មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព, សហគ្រិនខ្មែរ, ធនាគារ វីង និង ភ្ញៀវកិត្តិយសជាច្រើនរូបទៀតផងដែរ។

ពិធីបើកដំណើរការជាផ្លូវការនេះ ត្រូវបានរៀបចំឡើងដើម្បីជាការអបអរសាទរក្រុមធុរកិច្ចថ្មីទាំង ១០ ក្រុម ដែលត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងកម្មវិធី និង ការប្រកាសបើកជាផ្លូវការនូវកម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថលរដូវកាលទី ៤។ គួរបញ្ជាក់ផងដែរថា ធុរកិច្ចថ្មីទាំង ១០ ខាងលើក៏នឹងចូលរួមវគ្គបុរេពន្លឿនអាជីវកម្ម និង វគ្គពន្លឿនអាជីវកម្មជាបន្តទៀតដើម្បីសម្រួចគំនិតរបស់អាជីវកម្ម និង ពង្រឹងសមត្ថភាពរបស់ក្រុមត្រៀមខ្លួនធ្វើបទបង្ហាញទៅកាន់ដៃគូពាក់ព័ន្ធ និង សាធារណជនក្នុង «ថ្ងៃបទបង្ហាញសាធារណៈ» ដែលជាវគ្គផ្តាច់ព្រ័ត្រនៃកម្មវិធី។

កម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថលរដូវកាលទី ៤ ត្រូវបានរចនាឡើងដើម្បីពន្លឿន និង ជ្រោមជ្រែងក្រុមធុរកិច្ចថ្មីដែលផ្តល់ដំណោះស្រាយឌីជីថលសម្រាប់អាជីវកម្មប្រភេទ B2B, B2C, និង B2G លើគ្រប់វិស័យដែលមានសក្តានុពល។ កម្មវិធីនេះផ្តល់ការគាំទ្ររយៈពេល ១២ សប្តាហ៍ដល់ក្រុមធុរកិច្ចថ្មី ដែលរួមមានការបណ្តុះបណ្តាល, ការតម្រង់ទិស និង ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធបន្ថែមរួមមាន៖ Digital Payment Sandbox, CamDX, CamDigiKey, Khmer OCR, Semantic Search, Online Business Registration, Startup Cambodia Platform, AWS Activate Portfolio (មានតម្លៃរហូតដល់ ៥ ពាន់ដុល្លារ) ជាពិសេសទៀតធុរកិច្ចថ្មីក៏អាចភ្ជាប់បណ្តាញទំនាក់ទំនងជាមួយដៃគូសហការក្នុងតំបន់ផងដែរ។

គួរបញ្ជាក់ផងដែរថាកម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថលរដូវកាលទី ៤ ត្រូវបានរៀបចំឡើងដោយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រួមជាមួយ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ", ដោយមានការសហការរៀបចំដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, សហគ្រិនខ្មែរ, រួមជាមួយ មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព ហើយក៏មានការឧបត្ថម្ភពី ធនាគារ វីង និង ចូលរួមគាំទ្រជាដៃគូចែករំលែកចំណេះដឹង (Knowledge Partners) ពី

មជ្ឈមណ្ឌលសាន់វ៉ានវ៉ានុវត្តន៍រាជធានីភ្នំពេញ, មជ្ឈមណ្ឌលសាន់វ៉ានវ៉ានុវត្តន៍នៅប្រទេសវៀតណាម, Business Startup Support Centre, Quest Venture និង Impact Investment Exchange រួមទាំងដៃគូផ្សព្វផ្សាយ រួមមាន Fresh News, Technology Cambodia, និង Cambodia Investment Review ផងដែរ។

*ព័ត៌មានទំនាក់ទំនង៖*

*- អំពីកម្មវិធី៖ កញ្ញា អ៊ឹម ចន្ទី, លេខទូរសព្ទ៖ +៨៥៥ ៩៦ ២៧ ៦៣ ៥៧៨*

*- សម្រាប់ព័ត៌មានបន្ថែម៖ https://dpa.techostartup.center/*